ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

## សារជូនពរ

## សូមគោរពជូន

## សម្តេចកត្តាព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា

## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ

**សម្តេចកត្តាព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស ប្រកបដោយសេចក្តីសោមនស្សរីករាយ បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល មហាប្រសើរ ជូន **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ដើម្បីបំពេញសកម្មភាពមនុស្សធម៌និងដឹកនាំកាកបាទក្រហមកម្ពុជា ឱ្យទទួលបានជោគជ័យថ្មីៗបន្តទៀត។

នាឱកាសនេះ យើងខ្ញុំទាំងអស់គ្នា សូមកោតសរសើរចំពោះវីរភាពដឹកនាំដ៏ឈ្លាសវៃ របស់ **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ក្នុងកិច្ចខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី បំពេញភារកិច្ចដ៏ឧត្តុង្គឧត្តមក្នុងបុព្វហេតុបម្រើជាតិ មាតុភូមិនិងប្រជាជនប្រកបដោយឆន្ទៈមោះមុត។ **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ជាអ្នកដឹកនាំស្ត្រីដ៏ឆ្នើមមួយរូប ហើយក៏បានដើរតួនាទីយ៉ាងសំខាន់ រួមចំណែកជាមួយរាជរដ្ឋាភិបាល លើកកម្ពស់សេចក្តីថ្លៃថ្នូរ កិត្តិយស តួនាទីរបស់ស្ត្រីនៅក្នុងសង្គមកាន់តែទូលំទូលាយ ក្នុងនោះសកម្មភាពមនុស្សធម៌ជួយចែករំលែក និងដោះស្រាយរាល់ទុក្ខលំបាករបស់ប្រជាជនដែលទទួលរងគ្រោះមហន្តរាយផ្សេងៗបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាពខ្ពស់ ទទួលបានការគាំទ្រយ៉ាងច្រើនពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាឆ្នាំថ្មី ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមតាមជួយថែរក្សាការពារប្រោះព្រំ ជូន **សម្តេចកត្តាព្រឹទ្ធបណ្ឌិត** ឧត្តមភរិយា **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ព្រមទាំង**បុត្រាបុត្រី និងចៅប្រុសចៅស្រីជាទីស្រឡាញ់** សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកត្តាព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ៦រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៨: generalsec@mod.gov.kh